ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**********

ក្រសួងពាណិជ្ជកម្ម

លេខ ៣៦៨.ពណ.សណ.កប/ប្រក

ភ្នំពេញ, ថ្ងៃទី១៦ ខែ ធ្នូ ឆ្នាំ១៩៩៧

# ប្រកាស

## ស្តីពីនីតិវិធី

## របស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជ.សរកន ០៨៩៧_១៨៧ ចុះថ្ងៃទី ៧ សីហា ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម ដែលប្រកាសអោយប្រើប្រាស់ដោយ ព្រះរាជក្រម លេខ នសរកម ០១៩៦/១៦ ចុះថ្ងៃទី ២៤ មករា ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ. បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- ពិនិត្យលើសំណូមពរចាំបាច់នៃការងាររបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា

## សំរេច

ប្រការ១ : ប្រគល់សិទ្ធិអោយនាយកដ្ឋានកម្មសិទ្ធិបញ្ញា អនុវត្តនូវតួនាទីភារកិច្ច ដែលរដ្ឋបានប្រគល់ ដើម្បីធ្វើការចុះបញ្ជី និង ផ្តល់វិញ្ញាបនប័ត្រពាណិជសញ្ញានិងសេវាសញ្ញា ជូនដល់អតិថិជន ក្នុង និង ក្រៅប្រទេស នឹងដោះស្រាយរាល់បញ្ហាដែលកើតឡើងពីការចុះបញ្ជី ។

ប្រការ២ : នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវរួមសហការជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ការពារពាណិជសញ្ញានិងសេវាសញ្ញាអោយកាន់តែមានប្រសិទ្ធិភាពខ្ពស់ ដើម្បីធានាការទុកចិត្តពីអតិថិជន ក្នុង និង ក្រៅប្រទេស ដែលបានចុះបញ្ជីរួចហើយ ។

ប្រការ៣ : ថេរវេលានៃការការពារពាណិជសញ្ញាត្រូវបានកំណត់រយៈពេល ១០ ឆ្នាំ និងអាចបន្តចុះបញ្ជីជាថ្មីទៀត ក្នុង១០ឆ្នាំម្តង ។
ម្ចាស់ពាណិជសញ្ញាឬសេវាសញ្ញា ឬ តំណាងដែលបានទទួលសិទ្ធិ ត្រូវរាយការណ៍មកនាយកដ្ឋានកម្មសិទ្ធិបញ្ញា អំពីការប្រើប្រាស់ឬមិនបានប្រើប្រាស់នូវពាណិជសញ្ញាឬសេវាសញ្ញា នៅរៀងរាល់៥ឆ្នាំម្តង ។ ការខកខានមិនបានរាយការណ៍ ពាណិជសញ្ញាឬសេវាសញ្ញានោះ នឹងត្រូវលុបចេញពីបញ្ជី ។

ប្រការ៤ : ចំពោះអតិថិជនក្នុង និង ក្រៅប្រទេស ដែលមានបំណងចុះបញ្ជីពាណិជសញ្ញាឬសេវាសញ្ញា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ( នាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួងពាណិជ្ជកម្ម ) ត្រូវបំពេញសំនុំបែបបទ ព្រមទាំងបង់អាករ និង កំរៃដូចខាងក្រោម :
- ពាក្យសុំ ចុះបញ្ជី ( Application for Registration ) ០១ ច្បាប់
- លិខិតប្រគល់សិទ្ធិ ( Power of Attorney ) ដែលចុះហត្ថលេខាបញ្ជាក់ដោយ មេធាវី ឬ សារការី ( Notary public ) ០១ ច្បាប់
- គំរូពាណិជសញ្ញាចំនួន ១៥ ( 15 models of mark )
- បង់អាករក្នុងការចុះបញ្ជី ៥០ ដុល្លាអាមេរិក
- កំរៃក្នុងការចុះផ្សាយក្នុងព្រឹត្តិប័ត្រ ៥០ ដុល្លាអាមេរិក
- កំរៃស្រាវជ្រាវពាណិជសញ្ញា ( Search report ) ៥ ដុល្លាអាមេរិក ( ប្រសិនបើមានសំណូមពរពីអតិថិជន )

ប្រការ៥ : ការផ្តល់នូវលិខិតទទួលស្គាល់ និង វិញ្ញាបនប័ត្រជាផ្លូវការក្នុងការចុះបញ្ជីពាណិជសញ្ញា ឬ សេវាសញ្ញាជូនដល់អតិថិជនក្នុង និង ក្រៅប្រទេស គឺធ្វើឡើងក្រោយពេលដែលបានពិនិត្យលើសំនុំលិខិត សុំចុះបញ្ជី ដែលបានចាត់ទុកថាមានលក្ខណៈត្រឹមត្រូវនិងស្របច្បាប់ ។

ប្រការ៦ : ចំពោះពាក្យស្នើសុំចុះបញ្ជីណាដែលមិនមានលក្ខណៈត្រឹមត្រូវតាមច្បាប់នោះ ក្រសួងពាណិជ្ជកម្ម មានសិទ្ធិបដិសេធមិនចុះបញ្ជីជូន ឬ លុបពាណិជសញ្ញាឬសេវាសញ្ញានោះចេញពីបញ្ជីវិញ ប្រសិនបើ :

- ពាណិជសញ្ញាឬសេវាសញ្ញា នោះអាចធ្វើអោយសាធារណៈជនភ័ន្តច្រឡំ
- ពាណិជសញ្ញាឬសេវាសញ្ញា នោះប្រើប្រាស់ក្នុងវិស័យសាធារណៈ
- ពាណិជសញ្ញាឬសេវាសញ្ញា នោះបង្ហាញចរិតលក្ខណៈរបស់ទំនិញឬសេវាសញ្ញា ដែលពាក់ព័ន្ធ ដូចជា ប្រភេទ គុណភាព ឬ បរិមាណ...
- ពាណិជសញ្ញាឬសេវាសញ្ញា នោះមានទ្រង់ទ្រាយជាទំនិញ ឬ សំបកវេចខ្ចប់របស់ទំនិញ
- ពាណិជសញ្ញាឬសេវាសញ្ញា នោះផ្ទុយនឹងសីលធម៌ សណ្តាប់ធ្នាប់សាធារណៈ ទំនៀមទំលាប់ប្រពៃណី ឬ ច្បាប់ជាធរមាន ។
- ពាណិជសញ្ញាឬសេវាសញ្ញាដែលលួចរបស់គេមកស្នើសុំចុះបញ្ជី ដោយម្ចាស់ដើមទំនិញមិនបានដឹង ។
- មានភាពជាន់គ្នានឹងពាណិជសញ្ញាឬសេវាសញ្ញាដែលបានចុះបញ្ជីត្រឹមត្រូវ និង ស្របច្បាប់រួចហើយ ។

**ប្រការ៧** : អ្នកដែលក្លែងបន្លំ និង មានចេតនាលើការចុះបញ្ជីពាណិជសញ្ញាឬសេវាសញ្ញា សំរាប់ប្រើប្រាស់ជាផលប្រយោជន៍ខុសច្បាប់នោះ នឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៨** : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ តទៅ ។

រដ្ឋមន្ត្រី

ចម - ប្រសិទ្ធ

**ចម្លងជូន** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- មន្ទីរពាណិជ្ជកម្មខេត្ត - ក្រុង
- សភាពាណិជ្ជកម្មរាជធានីភ្នំពេញ
- ឯកសារ កាលប្បវត្តិ